# សូមឱ្យគុណធម៌តុបតែងគំនិតអ្នក

ប៊ីស្សព អេក ដេវីឌ ប៊េរតុន
ប៊ីស្សពអធិបតី

*យើងត្រូវការពារ ហើយត្រូវនឹងនរនៅក្នុងការអនុវត្តន៍គុណធម៌ដូចជាព្រះគ្រីស្ទ ។*

សូមអរគុណអែឌើរ ផេស សំរាប់ការអធិស្ឋានបើកដ៏ប្រពៃ និងជាពិសេស សូមអរគុណចំពោះអ្នកស្ដាប់ និងអ្នកឡើងនិយាយទាំងឡាយ ។

"សូមឱ្យគុណធម៌តុបតែងគំនិតអ្នក ដោយឥតឈប់ឈរឡើយ ខណៈនោះអ្នកនឹងមានចិត្តក្លាហានឡើងនៅចំពោះវត្តមាននៃព្រះ" (គ. និង ស. 121:45) ។

កាលខ្ញុំមានអាយុជិតបាន 12 ឆ្នាំ គឺខ្ញុំត្រូវធ្វើនូវរឿងមួយចំនួនជាមុនសិន ពីមុនខ្ញុំអាចបញ្ចប់ថ្នាក់កុមារបាន ។ តំរូវការមួយ គឺជាការសូត្រមាត្រានៃសេចក្ដីជំនឿទាំងដប់បីតាមលំដាប់លំដោយ ។ មាត្រាចំនួនដប់ពីរដំបូង គឺមានភាពងាយស្រួលណាស់ ប៉ុន្តែមាត្រាទីដប់បីមានការលំបាកណាស់ ។ ការចងចាំនូវលំដាប់លំដោយនៃគុណធម៌ទាំងនេះឯង គឺជារឿងដែលកាន់តែពិបាកថែមទៀត ។ អរគុណចំពោះគ្រូថ្នាក់កុមារម្នាក់ ដែលមានចិត្តអត់ធ្មត់ ស៊ូទ្រាំ ។ នៅទីបំផុត ខ្ញុំបានបំពេញការចងចាំរបស់ខ្ញុំបានសំរេច ។

ច្រើនឆ្នាំក្រោយមក ភរិយារបស់ខ្ញុំ និងរូបខ្ញុំ ព្រមទាំងកូនៗ បានផ្លាស់ទៅរស់នៅក្នុងផ្ទះដំបូងរបស់យើង ។ យើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយដឹងថា អតីតគ្រូថ្នាក់កុមាររបស់ខ្ញុំនឹងក្លាយជាអ្នកជិតខាងរបស់យើងនោះ ។ អស់រយៈពេល 40 ឆ្នាំ ដែលយើងរស់នៅក្នុងតំបន់ជាមួយគ្នា គាត់បានលាក់រឿងសម្ងាត់ដ៏តូចរបស់យើងទាក់ទងនឹងភាពខ្សោយនៅក្នុង ការរៀនសូត្ររបស់ខ្ញុំ ។

"យើងខ្ញុំជឿលើការប្រព្រឹត្តដោយទៀងត្រង់ ត្រឹមត្រូវ បរិសុទ្ធ សប្បុរស គុណធម៌ ហើយលើការធ្វើល្អដល់មនុស្សទាំងអស់ ពិតមែនហើយ យើងខ្ញុំអាចនិយាយបានថា យើងខ្ញុំដើរតាមសេចក្ដីដាស់តឿនរបស់ប៉ុល---យើងខ្ញុំជឿដល់អ្វីៗទាំងអស់ យើងខ្ញុំសង្ឃឹមដល់អ្វីៗទាំងអស់ យើងខ្ញុំបានទ្រាំទ្រអ្វីៗជាច្រើន ហើយសង្ឃឹមថា នឹងអាចទ្រាំទ្រអ្វីៗទាំងអស់បានដែរ ។ ហើយបើសិនជាមានអ្វីណាមួយ ដែលប្រកបដោយគុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឱ្យសរសើរ នោះយើងខ្ញុំស្វែងរករបស់ផងទាំងនេះហើយ" (មាត្រានៃសេចក្ដីជំនឿ 1:13) ។

នៅថ្ងៃនេះ ខ្ញុំមានបំណងចង់លើកឡើងពីផ្នត់គំនិតផ្ទាល់ខ្លួន ដែលយើងហៅថា គុណធម៌ ។ ផ្នត់គំនិតនៃគុណធម៌ បង្កើតជាគ្រឹះនៃជីវិតក្នុងភាពជាអ្នកជឿលើព្រះគ្រីស្ទ និងជាការបង្ហាញពីឥរិយាបថពិតរបស់យើងជាសាធារណៈផងដែរ ។ ការប្រកបពាក្យនៅក្នុងភាសាអង់គ្លេសសំរាប់ពាក្យគុណធម៌នីមួយៗបញ្ចប់ដោយអក្សរ *ity* រួមមានដូចជាពាក្យ : សច្ចៈធម៌ សេចក្ដីរាបសា សេចក្ដីសប្បុរស ជីវភាពខាងវិញ្ញាណ ការទទួលខុសត្រូវ គារវភាព ភក្តិភាព ជាដើម ។ អក្សរ *ity* ជាបច្ច័យ ដែលមានន័យថា គុណភាព ស្ថានភាព ឬក៏រិតរបស់មនុស្ស ។

ដើម្បីយល់ថាតើផ្នត់គំនិតនៃគុណធមិកំពុងថយចុះដល់កំរិតណា  នោះយើងគ្រាន់តែសម្លឹងមើលនៅជុំវិញខ្លួន  ពីអ្វីដែលកំពុងកើតឡើងនៅក្នុងសហគមន៍របស់យើងប៉ុណ្ណោះ។  សូមគិតពីឥរិយាបថរបស់ពួកអ្នកបើកបររថយន្ត  តាមដងមហាវិថីធំៗជាច្រើន។ ការបើកប្រជែងគ្នា គឺតែងកើតមានជាញឹកញាប់។ គារវភាពកំរនឹងកើតមានណាស់នៅក្នុង ការសន្ទនាផ្នែកនយោបាយរបស់យើង។ ខណៈដែលប្រទេសជាច្រើននៅជុំវិញពិភពលោកកំពុងប្រឈមមុខនឹងវិបត្តិផ្នែកហិរញ្ញវត្ថុ  និងផ្នែកសេដ្ឋកិច្ច  នោះភក្តីភាព  និងភាពស្មោះត្រង់ហាក់ដូចជាត្រូវបានជំនួសឱ្យដោយ  សេចក្តីលោភលន់  និងទ្រព្យសម្បត្តិទៅវិញ។  ការទៅលេងនៅឯវិទ្យាល័យមួយនឹងនាំឱ្យអ្នករាល់គ្នាឃើញពីការប្រើពាក្យសម្តីមិនសមរម្យ  និងសំលៀកបំពាក់មិនថ្លៃថ្នូរ។  មានពួកអត្តពលករមួយចំនួនបានបង្ហាញនូវការខ្វះភាពជាអ្នកកីឡា  ហើយកំរនឹងបង្ហាញពីឥរិយាបទរាបសាណាស់  លើកលែងតែត្រូវបានផ្សាយជាសាធារណៈអំពីការខ្វះភក្តីភាព  ចំពោះច្បាប់  និងសីលធមិប៉ុណ្ណោះ។ ផ្នែកដ៏ធំមួយនៃចំនួនប្រជាជនរបស់យើង  បានទទួលអារម្មណ៍តែបន្តិចបន្តួចប៉ុណ្ណោះ  ចំពោះការទទួលខុសត្រូវសំរាប់សុខុមាលភាពខាងសាច់ឈាមរបស់ខ្លួន។  មនុស្សមួយចំនួនដែលធ្លាក់ខ្លួននៅក្នុងវិបត្តិហិរញ្ញវត្ថុបានស្តីបន្ទោសដល់ធនាគារ  និងពួកអ្នកផ្តល់ប្រាក់កម្ចីសំរាប់ចំនួនសរុបនៃប្រាក់កម្ចី  ដើម្បីបំពេញឱ្យការចង់  បានដែលមិនចេះស្កប់ស្កល់ ជាជាងសេចក្តីត្រូវការស្របតាមលទ្ធភាពនោះ។ ពេលខ្លះ សេចក្តីសប្បុរសរបស់យើងនៅក្នុង ការគាំទ្រដល់បុព្វហេតុត្រឹមត្រូវមានការចុះអន់ថយ នៅពេលការចង់បានរបស់យើងមានទំហំធំធេងជាងសេចក្តីត្រូវការរបស់យើងនោះ។

បងប្អូនប្រុសស្រីទាំងឡាយ យើងមិនត្រូវធ្វើជាផ្នែកមួយនៃជម្ងឺដែលកំពុងជ្រាតចូល និងធ្វើការចម្លងដល់សង្គមឡើយ។ បើយើងធ្វើតាមពិភពលោកដោយបោះបង់ចោលនូវគុណធមិជាពួកអ្នកជឿលើព្រះគ្រីស្ទ  ជាលទ្ធផល  នោះរឿងមហន្តរាយអាចនឹងកើតមានឡើង។ សេចក្តីជំនឿ និងភក្តីភាព ដែលមានលទ្ធផលដ៏នៅអស់កល្បជានិច្ចនោះ នឹងថយចុះ។ សាមគ្គីភាពក្នុងគ្រួសារ និងជីវភាពខាងវិញ្ញាណនឹងទទួលរងនូវឥទ្ធិពលមិនល្អ។  សាសនាទាំងឡាយដែលជះឥទ្ធិពលនៅក្នុងសង្គមនឹងធ្លាក់ចុះ  ហើយក្រិត្យក្រមច្បាប់នឹងមានការកែប្រែ  ហើយថែមទាំងត្រូវបានគេបំភ្លេចចោលទៀតផង។  ប្រភពសំរាប់គ្រប់កិច្ចការទាំងអស់ដែលបង្កបញ្ហាដល់មនុស្សខាងសាច់ឈាមនឹងធ្វើឱ្យសាតាំងមានចិត្តរីករាយ។

យើងត្រូវការពារ  ហើយត្រូវនឹងនរដើម្បីអនុវត្តគុណធមិដូចជាព្រះគ្រីស្ទនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។  ការបង្រៀនពីផ្នត់គំនិតដែលមានគុណធមិ  ត្រូវចាប់ផ្តើមឡើងនៅក្នុងគេហដ្ឋាន  ដោយមានឪពុកម្តាយធ្វើជាគំរូ។ គំរូដ៏ល្អមួយរបស់ឪពុកម្តាយលើកទឹកចិត្តឱ្យមានការធ្វើតាម។  គំរូមិនល្អនឹងបង្កឱ្យកុមារទាំងឡាយមានការធ្វេសប្រហែសចំពោះការបង្រៀនរបស់ឪពុកម្តាយហើយថែមទាំងធ្វើឱ្យគំរូអាក្រក់នោះរីកធំឡើងៗទៀតផង។ គំរូដែលមានភាពលាក់ពុតនឹងបំផ្លាញនូវភាពជឿជាក់។

មានក្មេងស្រីម្នាក់អាយុប្រាំបីឆ្នាំឈ្មោះ  មេហ្គែន  ហើយនាងចូលចិត្តលេងព្យាណូណាស់។  ថ្មីៗនេះ  គ្រូបង្រៀនព្យាណូរបស់នាងបានផ្តល់រង្វាន់ជានំដូណាត់មួយចំពោះការហ្វឹកហាត់ដ៏ស្មោះត្រង់ជាប្រចាំថ្ងៃ។  គ្រូរបស់នាងបាននិយាយថា  ពេលខ្លះនៅថ្ងៃធម្មតាគាត់ត្រូវទូរស័ព្ទទៅ មេហ្គែន សំរាប់នំដូណាត់។ បើនៅថ្ងៃនោះ នាងបានហ្វឹកហាត់ នោះនាងនឹងទទួលបានរង្វាន់។ នៅពេលគាត់ទូរស័ព្ទទៅ មេហ្គែន គឺនាងមិនបាននៅផ្ទះចាំទទួលទូរស័ព្ទឡើយ។ នៅក្នុងការរៀនមេរៀនប្រចាំសប្តាហ៍ គ្រូបានសួរទៅ មេហ្គែន ថាតើនាងបានហ្វឹកហាត់ដែរឬទេ  នោះនាងបានឆ្លើយថា  នាងគិតថានាងបានធ្វើកិច្ចការនោះ  ហើយក៏បានទទួលនូវរង្វាន់ពីគ្រូរបស់នាង។ នៅពេលអ្នកម្តាយរបស់ មេហ្គែន បានឃើញនំដូណាត់នោះ នោះគាត់បានសួរទៅ មេហ្គែន ហើយបានជួយនាងឱ្យយល់ថា

នាងត្រូវតែមានភាពស្មោះត្រង់។ ដោយមានការលើកទឹកចិត្តពីសំណាក់អ្នកម្ដាយរបស់នាង នោះនាងក៏បានទូរស័ព្ទទៅសុំទោសដល់គ្រូរបស់នាង។ នៅពេលគ្រូ និងសិស្សជួបគ្នា ហើយឃើញថា មេហ្គែន បានបញ្ចប់ការសរសេរផ្នែកទ្រឹស្ដីតន្ត្រីរបស់នាង ដូច្នេះនាងអាចទទួលបានរង្វាន់។ សូមអរគុណចំពោះឪពុកម្ដាយឆ្លាតវៃ ដែលមានចិត្តខ្ពស់ខ្ពាយ ទើបធ្វើឱ្យមេរៀនដ៏មានតម្លៃទាំងឡាយនឹងត្រូវបានចងចាំជារៀងរហូត។

ចៅប្រុសរបស់យើងអាយុ 15 ឆ្នាំ ឈ្មោះ បិន ជាមនុស្សដែលចូលចិត្តលេងកីឡាជិះស្គី "បំផុត" ដោយចូលរួមនៅក្នុង ការប្រកួតមួយចំនួន ហើយបានធ្វើយ៉ាងប្រសើរបំផុត។ ពីមុនធ្វើកាប្រកួតមួយនៅរដ្ឋ អៃដាហូ ឪពុកម្ដាយរបស់គាត់បាន រំលឹកគាត់ថា គាត់អាចចូលរួមក្នុងការប្រកួតបាន ឬមិនបាន គឺអាស្រ័យទៅលើពិន្ទុរបស់គាត់នៅឯសាលារៀន។ ផ្ទះមួយនៅក្នុងសាន់វ៉ាលី រដ្ឋអៃដាហូ ត្រូវបានធ្វើការកក់ទុក ហើយលោកតាលោកយាយរបស់គាត់បានមាន គំរោងនឹងចូលរួមផងដែរ ហើយ បិន បានព្យាយាមសំរេចឱ្យបាននូវគោលដៅសំរាប់ការសិក្សាដ៏ខ្ពស់បំផុត ដែលគាត់ ហើយនឹងឪពុកម្ដាយរបស់គាត់បានរំពឹងទុក។ ប៉ុន្តែ នៅទីបំផុតគាត់មិនអាចសំរេចគោលដៅរបស់គាត់បានឡើយ។ បិន បានខកខានមិនបានចូលរួមនៅក្នុងការប្រកួតជិះស្គី ហើយបាត់បង់ពិន្ទុដើម្បីអាចចូលជាកីឡាករថ្មីសំរាប់អូឡាំពិចផងដែរ ប៉ុន្តែ បិន បានទទួលនូវក្ដីរីករាយដ៏មានតម្លៃមួយចំពោះការទទួលខុសត្រូវ។ តាមរយៈការបន្តមានភាពរឹងមាំ ជាញឹកញាប់ឪពុកម្ដាយទាំងឡាយមានការរងទុក្ខ និងព្រួយបារម្ភច្រើនជាងកូនចៅរបស់ខ្លួនទៅទៀត។

ប្រធាន ជែមស៍ អ៊ី ហ្វោស្ដ បានណែនាំថា សច្ចៈធម៌ គឺជាប្រភពនៃគុណធម៌ជាច្រើនផ្សេងទៀត។ លោកបានសំគាល់ឃើញថា សច្ចៈធម៌អាចត្រូវបានគេឱ្យនិយមន័យថា "ជាភក្ដីភាពដ៏រឹងមាំចំពោះក្រិត្យក្រមនៃគុណតម្លៃសីលធម៌"។ លោកក៏បានណែនាំផងដែរថា "សច្ចៈធម៌ ជាពន្លឺដែលបំភ្លឺចេញពីមនសិកាដ៏ម៉ឹងម៉ាត់។ វាគឺជាកម្លាំងរបស់ព្រះអាទិទេពនៅក្នុងខ្លួនយើង" ("Integrity, the Mother of Many Virtues" នៅក្នុង *Speaking Out on Moral Issues* [ឆ្នាំ 1998] ទំព័រ 61,62)។ វាគឺជាការលំបាកសំរាប់មនុស្សម្នាក់ដើម្បីបង្ហាញពីផ្នត់គំនិត បើគេខ្វះសច្ចៈធម៌នោះ។ បើគ្មានសច្ចៈធម៌ទេ នោះជារឿយៗ ភាពស្មោះត្រង់នឹងត្រូវបានគេបំភ្លេចចោល។ បើគ្មានសច្ចៈធម៌ នោះគារវភាពនឹងថយចុះ។ បើសច្ចៈធម៌ពុំមែនជារឿងសំខាន់ នោះជីវភាពខាងវិញ្ញាណនឹងពិបាកថែរក្សាឱ្យគង់វង់ណាស់។ នៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ម៉ូសេ បានទូន្មានដល់កូនចៅអ៊ីស្រាអែលថា "បើបុរសណាបន់ដល់ព្រះយេហូវ៉ា ឬនឹងស្បថភ្ជាប់ខ្លួនដោយសម្បថណាមួយ អ្នកនោះមិនត្រូវក្បត់ពាក្យខ្លួនឡើយ គឺត្រូវតែធ្វើតាមសំដីរបស់ខ្លួនគ្រប់ជំពូក" (ជនគណនា 30:2)។

ប្រធាន ថូម៉ាស អេស ម៉ នសុន បានរំឭកយើងកាលពីប៉ុន្មានឆ្នាំមុនថា "មនុស្សភាគច្រើននឹងពុំមាននូវទង្វើរនៃភាពភ័យខ្លាចឡើយ បើពួកគេត្រូវបានបង្រៀនថា ភាពថ្លៃថ្នូរ ភាពស្មោះត្រង់ និងសច្ចៈធម៌មានសារៈសំខាន់ជាងការសងសឹក ឬកំហឹងនោះ។ ហើយបើពួកគេយល់ថា គារវភាព និងសេចក្ដីសប្បុរស គឺជាកត្តាដ៏សំខាន់ដើម្បីទទួលបានឱកាសនៃភាពជោគជ័យ' ("Family Values in a Violent Society" *Deseret News* ថ្ងៃទី 16 ខែ មករា ឆ្នាំ 1994 ទំព័រ A12 ក៏មានដកស្រង់នៅក្នុង "Finding Peace" *Liahona* ខែ មិនា ឆ្នាំ 2004 ទំព័រ 4 ផងដែរ)។

អ្នករាល់គ្នាប្រហែលជាធ្លាប់ឮរឿង កងពលវរសេនាតូចដែលអស់សង្ឃឹម រឿងកុលសម្ព័ន្ធអ៊ីស្រាអែលទាំងដប់ដែល បានបែកខ្ញែកគ្នា ឬប្រហែលជារឿង ក្មេងប្រុសបាត់ខ្លួននៅក្នុងការសម្ដែងរបស់ ជី.អិម បារី ដើរតួជា *ភីធើរ ផាន*។ អ្នករាល់គ្នាក៏អាចនឹងស្គាល់ពីតន្ត្រីរបស់លោកម៉ៃខល ម៉ាក់លីន ដែលមានចំណងជើងថា "ចម្រៀងថ្ងៃបុណ្យគ្រីស្ទម៉ាសដែលបាត់បង់" ដែរ ។ ផ្នត់គំនិតនៃគុណធម៌មិនគួរត្រូវបានគេបំភ្លេចចោល ឬមិនអើពើនោះឡើយ ។ បើត្រូវបានគេបំភ្លេច ចោលឬទុកចោល នោះវានឹងក្លាយទៅជាគុណធម៌ដែល"បាត់បង់ជាក់ជាពុំខានឡើយ" ។ បើគុណធម៌ទាំងនេះបាត់បង់ទៅ នោះក្រុមគ្រួសារនឹងមានភាពទន់ខ្សោយបំផុត ហើយសេចក្ដីជំនឿរបស់បុគ្គលទាំងឡាយលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទនឹងមានភាពទន់ជ្រាយ ហើយទំនាក់ទំនងដ៏សំខាន់សំរាប់ភាពដ៏នៅអស់កល្បជានិច្ចអាចនឹងគ្រោះថ្នាក់ ។

គុណធម៌ដែលបានអនុវត្តយ៉ាងទូលំទូលាយ អាចនឹងបន្ទូរការចាប់គ្រៀកយ៉ាងណែនរបស់សាតាំងនៅក្នុងសង្គម ហើយងាកចេញពីផែនការបោកបញ្ឆោតរបស់វា ដើម្បីចាប់ចងដួងចិត្ត គំនិត និងវិញ្ញាណរបស់មនុស្សក្នុងជីវិតរមែងស្លាប់ ។

ឥឡូវនេះ គឺជាពេលសំរាប់យើងដើម្បីចូលរួមក្នុងការជួយសង្គ្រោះ និងការពារ អ្វីដែលប្រកបដោយ"គុណធម៌ គួរស្រឡាញ់ និងឈ្មោះល្អ និងគួរឱ្យសរសើរ" ។ នៅពេលយើងអនុញ្ញាតឱ្យគុណធម៌តុបតែងគំនិតយើង ដោយឥតឈប់ឈរ ហើយយើងបណ្ដុះផ្នត់គំនិតនៃគុណធម៌នៅក្នុងជីវិតរស់នៅរបស់យើង នោះសហគមន៍ និងស្ថាប័នរបស់យើងនឹងមានភាពបសើរឡើង ហើយកូនចៅ និងគ្រួសាររបស់យើងនឹងមានភាពរឹងមាំ ហើយសេចក្ដីជំនឿ និងសេចក្ដីស្មោះត្រង់នឹងប្រទានពរដល់ជីវិតរបស់បុគ្គលម្នាក់ៗ ។

ខ្ញុំថ្លែងទីបន្ទាល់ និងប្រកាសថា ព្រះវរបិតាសួគ៌របស់យើង រំពឹងចង់ឱ្យកូនចៅរបស់ទ្រង់ អនុវត្តសច្ចៈធម៌ សេចក្ដីរាបសា ភក្ដីភាព សេចក្ដីសប្បុរស សណ្ដានចិត្តល្អ សីលធម៌ និង គ្រប់គុណធម៌ ។ សូមឱ្យយើងមានភាពរាបសារដើម្បីឆ្លៀតឱកាសធ្វើកិច្ចការទទួលខុសត្រូវរបស់យើង ដើម្បីបង្ហាញសមត្ថភាពរបស់យើងដើម្បីធ្វើដូច្នោះបាន ខ្ញុំអធិស្ឋាននៅក្នុងព្រះនាមដ៏ពិសិដ្ឋនៃ ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។